# សង្គ្រាម និង សន្តិភាព

តាមស្នាម ប្រវត្តិសាស្ត្រនៅស្រុកខ្មែរ ទោះបីមានសង្គ្រាម ឬមាន សន្តិភាព នៅក្នុងស្រុកក្តី, ចំពោះ បណ្តារាស្ត្រ នៅក្នុង ស្ថានភាព ទាំងពីរយ៉ាងនេះ វាគ្មាន អ្វីខុស ផ្លែកគ្នា ដាច់ស្រឡះ សំរាប់ការ រស់នៅ របស់ខ្លួន នោះឡើយ ព្រោះភាពក្រលំបាក ជាហេតុ នៃ ទុក្ខក្ខន្ទ (ទុក្ខគ្រប់បែបយ៉ាង) ជានិច្ចកាល របស់ខ្លួន។ គួរខ្មែរ យើង គិតពិចារណា បន្តិច អំពី ស្ថានភាព បច្ចុប្បន្ននេះ ដែល យើងទុកជា ស្ថានភាព មាន សន្តិភាព នៅស្រុកខ្មែរ, តែយើង ឃើញថា បងប្អូនខ្មែរ ចំនួន ជាង ១ លាននាក់ នាំគ្នា ចាក ចេញពី ស្រុកខ្មែរ ដើម្បី ទៅរក ការងារធ្វើ សំរាប់ ចិញ្ចឹម ជីវិត គ្រួសារ នៅបរទេស, ជា ពិសេស នៅ ប្រទេសសៀម, ហាក់បីដូច ជា នៅក្នុង ស្រុក របស់ខ្លួន មាន សង្គ្រាម។

ដូចគ្នានោះដែរ, នៅតាម ជនបទ, ជនខ្មែរ ភាគច្រើន នាំគ្នា ចាកចេញពី លំនៅដ្ឋាន ទាំងហ្វូង ដើម្បី មករង ការងារធ្វើ ក្នុងរោងចក្រ នៅតាម ទីក្រុងនានា។ ស្ថានភាពនេះ វា ប្រហាក់ ប្រហែលគ្នានឹង ស្ថានភាព សង្គ្រាម ដែលនាំឲ ខ្មែរយើង រត់ ចោល ប្រទេស ឬ ចាកចេញពី ភូមិកំណើត ព្រោះ ចង់គេចពី សង្គ្រាម, ដូចគ្នាដែរនឹង ការគេចពី សេចក្តីក្រីក្រ នៅពេល ស្រុក មាន សន្តិភាព។ មកដល់ ចំណុចនេះ យើងអាច ប្រដូច

# សង្គ្រាម និង សន្តិភាព

គ្នាបានថា សង្គ្រាម និង ភាពក្រីក្រ វា មាន ធាតុ ជា ទុក្ខក្ខន្ធ ដូចគ្នា សំរាប់ ប្រជារាស្ត្រខ្មែរ។

ដូច្នេះ, យើង មិនមាន មតិស្របនឹង ខ្មែរយើងខ្លះ, គាត់ មាន យោបល់ ដាច់ខាត ថា សង្គ្រាម ជា កត្តា បង្កើត សេចក្តីក្រីក្រ, ចំពោះយើង, យើង មាន យោបល់ ផ្ទុយ ទៅវិញ ថា, សេចក្តីក្រីក្រ ដែល មាន ជានិច្ចកាល ក្នុង សង្គមខ្មែរ ទេ វា ជា កត្តា បង្កើត ញឹកញាប់ នៃ សង្គ្រាម រវាង ខ្មែរ នឹង ខ្មែរ និង សង្គ្រាម ឈ្លានពាន ពីសំណាក់ ប្រទេសជិតខាង។

ដូច្នេះទៀត, យើងអាច សន្និដ្ឋានបានថា ភាពក្រីក្រ ដែលមាន ជានិច្ចកាល របស់ ប្រជាពលរដ្ឋខ្មែរ វា ជា សង្គ្រាម ត្រដាក់ ជា អចិន្ត្រៃយមួយ នៅកម្ពុជា។ ដើម្បី បន្ត ការយល់ឃើញ របស់ យើង ក្នុងចំណុច ខាងលើនេះ, យើង លើក ករណី នៃ សន្តិភាព និង គោលដៅ របស់វា មកពិនិត្យ នៅទីនេះ។ ខ្មែរយើង មួយ ភាគធំ តែងតែ លើក គុណូបការ (mérite) នៃ ថ្ងៃ ទី២៣ តុលា ១៩៩១ ទុកជា ថ្ងៃ បញ្ចប់ សង្គ្រាម រវាង ភាគីយុទ្ធការីខ្មែរ គឺជា ថ្ងៃ សន្តិភាព សំរាប់ ប្រជាជាតិខ្មែរ។ ចំពោះ ការយល់ឃើញនេះ, បើយើងនាំគ្នា ទុក សន្តិភាព ជា វត្ថុ ដែល វិសេស សំរាប់ តែ ន័យ របស់ ពាក្យ តែ ប៉ុណ្ណោះ, តែមិនគិតពី គោលដៅ និង សមិទ្ធិកម្ម របស់វា, យើង មានការយល់ស្រប ទាំងស្រុង ថា ថ្ងៃទី ២៣ តុលា គឺ ពិត ជា ថ្ងៃ នៃ ផ្នែកដើម នៃ សន្តិភាពខ្មែរពិតមែន។ តែ បើយើងនាំគ្នា ពិនិត្យ អំពី គោលដៅ និង សមិទ្ធិកម្ម

# សង្គ្រាម និង សន្តិភាព

របស់វា រហូត មកដល់ បច្ចុប្បន្នកាលនេះ យើងឃើញវា មាន ការងាកចេញពី គោលដៅ ដែលបាន កំណត់ទុក ពីដើមទីម ក។ ការងាកចេញនេះ ជា ការកែប្រែមួយ ដ៏សំខាន់ នៃ សារ ជាតិ របស់សន្តិភាព កើតចេញពី ថ្ងៃ ទី២៣ តុលា នេះ។ ឬមួយ មកពី កិច្ចព្រមព្រៀង សន្តិភាព ថ្ងៃ ទី២៣ តុលា, វាមិនល្អ?, ឬមួយ មកពី ការអនុវត្ត វាមិនមាន ភាពត្រឹមត្រូវ ?

ដើម្បី ឆ្លើយ នឹងសំណួរនេះ, យើង គួរត្រឡប់មក ពិនិត្យមើល គោលដៅ របស់ សន្តិភាពនេះសិន។ យើងដឹងថា,សន្តិភាពនេះ, វាមាន គោលដៅ សំខាន់មួយ គឺ, ការស្ថាបនា នៃ លទ្ធិប្រជាធិ បតេយ្យ ឲទៅជា ស្ថាប័នជាតិ ដែល គេទុកជា ឫស នៃ សន្តិ ភាព សំរាប់ ប្រជាជាតិខ្មែរ។ ក្នុងការស្ថាបនានោះ, អ.ស.ប គេ តម្រូវឲ ភាគីខ្មែរ និមួយៗ បោះបង់ មនោគមវិជ្ជា នយោបាយ រៀងខ្លួន, ហើយនាំគ្នា យក លទ្ធិប្រជាធិបតេយ្យសេរី ជា មូល ដ្ឋាន សំរាប់ រកដំណោះស្រាយ ក្នុង ជម្លោះ រវាង ខ្មែរនឹងខ្មែរ។ យើងសួរទៅទៀតថា, នៅពេលនោះ, អ្វីទៅជា ធាតុ នៃ ជម្លោះ រវាង ខ្មែរ នឹង ខ្មែរ? ជា ធាតុ មនោគមវិជ្ជា ? បើ យើងនាំគ្នា ពិនិត្យមើលវា ឲបានច្បាស់លាស់, យើងឃើញថា, នៅពេលនោះ ធម្មជាតិពិត នៃ សង្គ្រាម នៅស្រុកខ្មែរ គឺជា សង្គ្រាម រំដោះ ស្រុកខ្មែរ ពី ការកាន់កាប់ នៃ កងទ័ពយៀកណាម, ដូច្នេះ នៅ ពេល ដែល យៀកណាម ប្រកាស ដកទ័ព ថយពី កម្ពុជា, ភាគី ខ្មែរ ដែល យៀកណាម គេបង្កើតឡើង សំរាប់ ធ្វើជា ឡប់ឡែគេ

# សង្គ្រាម និង សន្តិភាព

ក៏បាន ក្លាយជា ភាគីខ្មែរ ពេញមុខ ក្នុង កិច្ចព្រមព្រៀងសន្តិភាព នៅចំពោះមុខ ភាគី បីទៀត ដែល ជា ភាគី ជា បច្ចាមិត្ត នៃកងទ័ពយៀកណាម នៅកម្ពុជា។ ក្នុងចំណុចនេះ,យៀកណាម ទទួលបាន ជ័យជំនិះ បីយ៉ាង :

១. យៀកណាម ធ្វើ សង្គ្រាម ឲក្លាយទៅជាសង្គ្រាម ខ្មែរ នឹងខ្មែរ, ដោយ គ្រាន់តែ ប្រកាសថាខ្លួន បាន ដកទ័ព ចេញពី កម្ពុជា,ដោយ ដឹងច្បាស់ថា អ.ស.ប. គ្មាន សម្ថភាព អ្វី នឹងត្រួត ពិនិត្យ ឲបានច្បាស់លាស់ នៃ ការដកកងទ័ព នោះឡើយ, ហើយ ទីបំផុត តម្រូវជឿខ្លួន តែម្តង,

២. យៀកណាម ជួយ ឧបត្ថម រដ្ឋាភិបាលខ្មែរ រណបខ្លួន ឲមាន មុខមាត់ ជា ភាគី ពេញមុខ លើ ឆាកអន្តជាតិក្តី, លើ ឆាក ជាតិក្តី, ក្នុង កិច្ចប្រជុំ រកដំណោះស្រាយ សន្តិភាព, ដោយ រក្សា កងទ័ពខ្លួន នៅក្នុង ជួរ កងទ័ពខ្មែរ, ដែល នាំឲកងទ័ពខ្មែរ នោះ អាចមាន លទ្ធភាព ធ្វើ សម្លាត តាមផ្លូវ យោធា ទៅលើ ពួកខ្មែរ ប្រឆាំងនឹងខ្លួន,

៣. យៀកណាម ធ្វើ នយោបាយ បំបែក កម្លាំង តស៊ូរ ប្រឆាំង នឹងខ្លួន ឲក្លាយជា បីភាគី វិញ នៅចំពោះមុខ ភាគីខ្មែរ រណប ខ្លួន ដើម្បី ងាយស្រួល ប្រើ មធ្យោបាយ បញ្ឆោត ភាគី ទាំងនោះ ឲបែក កម្លាំងរួម, ហើយ ស្វែងរកតែ ប្រយោជន៍ខ្លួនឯង។ ក្នុង

# សង្គ្រាម និង សន្តិភាព

យុទ្ធសាស្ត្រនេះ,យៀកណាម,គេ សម្លឹងឃើញច្បាស់ថា សម្តេច សីហនុ ជា កងប្រវាក់ ខ្សោយ ជាងគេ បំផុត ក្នុងកម្លាំងរួម សំរាប់គេ បញ្ឆោត ឲចូលក្នុង អន្ទាក់ របស់គេ។ ជ័យជំនិះ ទាំងបីយ៉ាងនេះ, នាំឲយើង មើលឃើញថា, កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា, មាន បលិពោធ (ការខ្វះ) ខ្លាំងណាស់ ក្នុង សេចក្តីម៉ឹងម៉ាត់ របស់វា, ហាក់បីដូចជា ប្រទេស ហត្ថលេខី ទាំងឡាយ, នាំគ្នា ភ្លេចគិត អំពី លទ្ធភាព នៃ ការព្យាបាទ (possibilité de nuire) របស់ យៀកណាមកុម្មុយនិស្ត, ដែលជា តួសំខាន់មួយ ក្នុង សង្គ្រាមខ្មែរ ក្នុងពេលនោះ, ដូចគ្នានឹង កិច្ចព្រមព្រៀង នៃ ការបញ្ចប់ សង្គ្រាម នៅយៀកណាម រវាង អាមេរិកាំង នឹង សាធារណរដ្ឋ ប្រជាមានិតយៀកណាម និង សារណរដ្ឋយៀកណាមខាងត្បូង នឹង រដ្ឋាភិបាលបដិវត្តន៏ បន្ដោះអាសន្ន យៀកណាមខាងត្បូង,នៅថ្ងៃ ទី២៧ មករា ឆ្នាំ១៩៧៣ នៅទីក្រុងបារីស។ បលិពោធនោះ គឺ កង្វះ អង្គការ ត្រួតពិនិត្យ, មុនពេល, ក្នុងពេល,និង ក្រោយពេល, ការចុះហត្ថលេខា កិច្ចព្រមព្រៀងសន្តិភាពនោះ,ទោះបីយើងយក ការបោះឆ្នោត ក្នុង ឆ្នាំ ១៩៩៣ ជាជោគជ័យ នៃ កិច្ចព្រមព្រៀង ២៣ តុលា យ៉ាងណា ក៏ដោយ, តែយើងឃើញថា វា មានភាព ស្រួយណាស់ និង អចិរភាព (មិនឋិតថេរ) គឺ ថា :

# សង្គ្រាម និង សន្តិភាព

១. ឲគណបក្ស ប្រជាជន, ជា គណបក្សចាញ់ឆ្នោត, មាន លទ្ធភាព មិនព្រម ទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត, ធ្វើអភិទ្រោះ(គំរាម) បង្កើត ដំបន់ អបគមន៏ ថែមទៅទៀត,

២. ទុក ឱកាសឲ ភាគីខ្មែរ និមួយៗ បង្កើត អស្ថិសុខ យោធាផង, នយោបាយផង,ជា កត្តា នាំឲមាន ផ្ទុះ អាវុទ្ធ នៅ ឆ្នាំ ១៩៩៧,ដែលនាំឲ គណបក្ស ប្រជាជន ក្លាយ ជា គណបក្ស កាន់អំណាចផ្តាច់ការ រហូតមកដល់សព្វថ្ងៃ,

៣. ទុកឱកាសឲ យៀកណាម បន្ត ធ្វើ នយោបាយ វាត ទឹកដី ដោយមាន ការគាំទ្រ ពីសំណាក់ អ្នកកាន់ អំណាច បច្ចុប្បន្ន, ដោយយក ច្បាប់ខ្មែរ ជា ការធានា នយោបាយនេះ។ រាជរដ្ឋាភិបាលខ្មែរ រណបយៀកណាម អនុញ្ញាតឲ ជនជាតិយួន រាប់លាន

នាក់ ចូលមក រស់នៅ ក្នុង ស្រុកខ្មែរ ក្នុង ឋានៈ ជា យួនខ្មែរ (យួនកាន់កាតខ្មែរ), មាន សិទ្ធិ ជាងពលរដ្ឋខ្មែរ ទៅទៀត។ សន្តិភាពបែបនេះ, តើ ខ្មែរយើង អាចចាត់ទុក ជា សន្តិភាពពិតបាន ដែរឬទេ ? បើសិនជា ខ្មែរយើ យល់ឃើញថា សន្តិភាពបែបនេះ ជា ការបន្ត សង្គ្រាម ដោយគ្រាន់តែ ដូរ រូបភាព ពី សង្គ្រាមក្តៅ ឬ អាវុធ មកជា សង្គ្រាម ត្រជាក់នោះ, យើង អាចធ្វើអនុមានបានថា កិច្ចព្រមព្រៀង ២៣ តុលា ជា កិច្ចព្រមព្រៀងសន្តិភាពមួយ មិនល្អ ក្នុង អន្តរវត្តុ ផង និង ក្នុង ការអនុវត្ត ផង។ យើងដឹងថា, អ្វី ដែលត្រូវធ្វើ, មិនមែន គ្រាន់តែ ទុក ការកំណត់ គោលដៅ ជា ទីបញ្ចប់នោះទេ, គឺ ផ្លូវដើរ ទៅរក គោល

# សង្គ្រាម និង សន្តិភាព

ដៅនោះ ជា កត្តា សំខាន់បំផុត, ព្រោះថា បើយើង ដើរលើផ្លូវល្អ ទោះយូរឆាប់ គង់តែដល់ គោលដៅ, តែ បើយើងដើរ ផ្លូវលើ ខុស, ទោះបី ខំដើរ យ៉ាងណា ក៏ដោយ, ក៏យើង មិនអាច ទៅ ដល់ គោលដៅ បាននោះដែរ, ព្រោះ វា ជា អសញ្ញកម្ម (ដំណើរ អស់ជីវិត ) រួចស្រេច ទៅហើយ។

យើងនិយាយនេះ មិនបាន សេចក្ដីថា, យើង ទុក កិច្ចព្រម ព្រៀងសន្តិភាព ២៣ តុលា ជា អសារ និង អសាធុ (អាក្រក់) នោះឡើយ សំរាប់ ប្រជាពលរដ្ឋខ្មែរ, ព្រោះ កិច្ចព្រមព្រៀងនេះ, វា មាន ប៉ែកវិជ្ជមានវា គឺ, ការសង្ឃឹមថ្មីមួយ របស់ ប្រជាពលរដ្ឋ ខ្មែរ ដែល បានរស់នៅ ក្នុង រណ្ដៅ ទុក្ខ អស់រយះពេល ពីរ ទសវត្ត (១៩៧០-១៩៩០) មកហើយ, តែ ការសង្ឃឹមនេះ វា ឋិតនៅលើ ប្រជាពលរដ្ឋ ទាំងស្រុង ព្រោះ វា កើតឡើង សំរាប់ ប្រជាពលរដ្ឋ ដែល គេ ទុក ជា ម្ចាស់ វាសនា របស់ខ្លួន, បើខ្លួន ទុកឲ ការ សង្ឃឹមថ្មីនេះ ជា ការស្រមៃ តែប៉ុណ្ណោះ, ទោះបី កិច្ចព្រមព្រៀង គ្មាន កង្វះតិចច្រើន យ៉ាងណា ក៏ដោយ, ក៏វា ពុំអាចមាន ប្រសិទ្ធភាព ក្នុង ការស្រមៃបាននោះដែរ ព្រោះ ការស្រមៃ ជា អំពើ អកម្ម។

ប៉ុន្តែ សេចក្ដីសង្ឃឹម ជា អំពើសកម្ម, តម្រូវឲមាន ការចូលរួម យ៉ាងសកម្ម ពីសំណាក់ ប្រជាពលរដ្ឋ, ដើម្បី ស្ថាបនាវា ឲក្លាយ ជា សេចក្ដីពិត មួយមែន។ ដូច្នេះ សន្តិភាព ២៣ តុលា គឺជា ផ្លូវ ដើរ ដ៏វែងឆ្ងាយមួយ ក្នុង សេចក្ដីសង្ឃឹម របស់ ប្រជាពលរដ្ឋខ្មែរ

# សង្គ្រាម និង សន្តិភាព

,ដែល មាន ជំនឿ លើ កម្លាំង មាន អំណាត់ របស់ខ្លួន សំរាប់ ដំណើរ ដ៏យូរអង្វែងមួយ។ ដំណើរនេះ តែងតែ ជួបឧបសគ្គ គ្រប់បែបយ៉ាង, តម្រូវឲ អ្នកដើរ មាន មានៈ កំទេច ឧបសគ្គ នេះ ដើម្បី បន្តដំណើរខ្លួន តទៅមុខទៀត។ ក្នុង ទស្សនៈណា មួយ ដែល ទុក សន្តិភាព ២៣ តុលា ជា ផល ទទួលរួចបាន ហើយជា ទស្សនៈ ភាន់ច្រឡំ ព្រោះ ដូច យើងបាននិយាយ រួច ហើយថា, សន្តិភាពនេះ ជាផ្លូវបន្តដើរ, មិនមែន ជា កន្លែង ដែល មកដល់ហើយ នោះទេ។

ការទាមទារ រៀងរាល់ ឆ្នាំ ពីសំណាក់ បងប្អូនខ្មែរ ឲគ្រប់ ភាគី ជាហត្ថលេខី គោរព កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា គឺជា ការទាមទារមួយ ឈរលើ គំនិត ទុក កិច្ចព្រមព្រៀង ជា កន្លែង មកដល់ ហើយនោះឯង ព្រោះ យើង សង្កេតឃើញថា ២១ ឆ្នាំ កន្លង ផុតរួច មកហើយ ក្រោយពីបាន ធ្វើបាតុកម្ម ប្រចាំឆ្នាំ រួចហើយ ក៏នាំគ្នា ដេកចាំ ធ្វើ វា ឆ្នាំក្រោយទៀត ជា ពិសេស គណបក្សប្រឆាំង គឺ គាត់ យក ពាក្យ ប្រឆាំង មកប្រើ ជានិច្ច ក្នុងថ្ងៃ ធ្វើបាតុកម្ម ប្រចាំឆ្នាំ តែ បន្ទាប់មក គាត់ នាំគ្នា ដេក សោយផល សន្តិភាព ២៣ តុលា ដែល គាត់ ជឿជាក់ ក្នុងចិត្ត ថា,ជា សន្តិភាពពិត នោះឯង ព្រោះ គាត់ មាន ចំណេញ ជា ផលទុនពីវា។ ជំនឿនេះឯង ដែលនាំឱ្យ គណបក្សប្រឆាំង ទុក ការបោះឆ្នោត គ្មានសេរី និង គ្មានយុត្តិធម៌ ជា ប្រភព ផលទុន និង អត្ថិភាព នយោបាយ របស់ខ្លួន។ យើងដឹងថា, ផលទុន,

# សង្គ្រាម និង សន្តិភាព

និង អត្ថិភាពនេះ, គណបក្សកាន់អំណាចផ្តាច់ការ គេ មិន មាន ចិត្តកំណាច់អ្វី នឹងឲទៅ គណបក្សប្រឆាំង នោះឡើយ ព្រោះ ការចែក ជា ចំណែក តូចនេះ ក៏ជា ប្រយោជន៏មួយ សំរាប់គេដែរ គឺ, សំរាប់ ជា មូលដ្ឋាន អំណាច ស្របច្បាប់ របស់គេ, តែទោះបីយ៉ាងណា, អំណោយ អាសនៈ នៅក្នុង រដ្ឋសភា ដែល គេទុកឲ គណបក្សប្រឆាំង មិនឲលើស ពីចំនួនមួយ ដែលនាំ រំខានដល់ ការគ្រប់គ្រង អំណាច របស់គេ, ចំនួននោះ គឺ ក្រោម ៣០ អាសនៈ ព្រោះ ចាប់ពី ចំនួន ៣០ទៅ អ្នកប្រឆាំង អាច ប្រើ មាត្រា ៩៨ នៃ រដ្ឋធម្មនុញ្ញ ធ្វើញត្តិ បន្ទោស រដ្ឋាភិបាល បាន (motion de censure) ដែល អ្នកកាន់អំណាច គេទុកជា ការ រំខានដល់ អំណាចផ្តាច់ការ របស់គេ។ យើងឃើញថា នៅស្រុក ខ្មែរសង្គ្រាម និង សន្តិភាព សំរាប់ប្រជាពលរដ្ឋ វា គ្មាន ភាព ផ្ទុយគ្នា នោះឡើយ ព្រោះ អ្នកកាន់អំណាច គាត់ នៅតែតាំង ខ្លួន ជា ម្ចាស់អំណាច ជានិច្ច ជា ពិសេស ទៅទៀត នៅក្នុង សន្តិ ភាព គ្មាន ប្រជាពលរដ្ឋ ជា ម្ចាស់អំណាចនេះហើយ ដែល ពួក អ្នកកាន់អំណាចផ្តាច់ គេ ប្រើប្រាស់ ការបោះឆ្នោត គ្មានសេរី និង គ្មាន យុត្តិធម៌ សំរាប់ ទាញយក ប្រយោជន៏ ដល់គេ គឺ,ពង្រឹង អំណាចផ្តាច់ការ ឲស្រប ច្បាប់ តែប៉ុណ្ណោះ។ អំណាច ស្របច្បាប់ នេះឯងហើយ ដែល ជា ខ្សែក្រវាត់ សន្តិសុខ របស់គេ ក្នុង ទំនាក់ទំនង លើ ឆាកអន្តរជាតិ ដែល វា តែងតែ គោរព ជានិច្ច ដល់រដ្ឋាភិបាល ស្របច្បាប់ របស់ប្រទេសនីមួយៗ។

# សង្គ្រាម និង សន្តិភាព

ឧទាហរណ៏ ជាក់ស្តែងមួយ ដែល ខ្មែរ ឥតអាចបំភ្លេចបាន គឺ, សន្តិភាព ក្នុង របបខ្មែរក្រហម ដែល ជា សន្តិភាពមួយ សំរាប់ ឲ ពួកអ្នកដឹកនាំ សម្លាប់ ប្រជាជនខ្មែរ តាមសេរី ឥតមាន នរណា ការពារបាន ព្រោះ រដ្ឋាភិបាល ខ្មែរក្រហម ជា រដ្ឋាភិបា ល ស្របច្បាប់ជាតិខ្មែរ។

យើង គ្មានបំណង ធ្វើការប្រៀបធៀប សន្តិភាព បច្ចុប្បន្ន នឹង សន្តិភាព ក្នុង របបខ្មែរ ក្រហម ថា វា ដូចគ្នា ១០០% នោះឡើយ តែ ខ្មែរយើង ត្រូវដឹងថា អ្នកកាន់អំណាច បច្ចុប្បន្ន សុទ្ធ ជា អតីត ខ្មែរក្រហម ដែលនាំ គ្នាស្ម័គ្រ បំរើ នយោបាយ យៀកណាម ដែល គេ មាន គោលបំណង តែមួយគត់ គឺ, ការលេបកម្ពុជា ចូលក្នុង ពោះ ឥណ្ឌូចិន ថ្មីមួយ ដែល មាន យៀកណាម និង ប្រជាជនយួន ជា ម្ចាស់ របស់ ប្រជាពលរដ្ឋខ្មែរ និង លាវ។ នយោបាយ លេប ស្រុកខ្មែរ នេះឯង វា ជា អំពើ សម្លាប់ ជាតិ សាសន៍ខ្មែរ នោះឯង។ ក្នុងចំណុច នេះហើយ ដែលយើង មើល ឃើញថា សន្តិភាព បច្ចុប្បន្ន វា ដូចគ្នានឹង សន្តិភាព ក្នុង របប ប៉ុល ពត នោះឯង។ តែ ប្រជាពលរដ្ឋខ្មែរ គាត់ អាចនឹងធ្វើឲ សន្តិភាព បច្ចុប្បន្ន ខុសដាច់ស្រឡះ ពីសន្តិភាព ‹‹ខ្មែរក្រហម››, បើ គាត់ មាន សេចក្តីក្លាហាន ហ៊ាន ដូរ ចរន្តន យោបាយ សព្វ ថ្ងៃ, សេចក្តីក្លាហាននោះ គឺ ជា សេចក្តីក្លាហាន អហិង្សា នាំគ្នា ប្រកាស ធ្វើពហិការ នៃ ការបោះឆ្នោត គ្មានសេរី និង គ្មាន យុត្តិធម៌,ថ្នាក់ជាតិ ក្នុង ឆ្នាំ ២០១៣ នេះ។ ពហិការនេះ ជា សិទ្ធិ

# សង្គ្រាម និង សន្តិភាព

របស់ ប្រជាពលរដ្ឋ, ជា អំពើ នយោបាយ សំខាន់ សំរាប់ បង្ហាញ នូវ អំណាច របស់ខ្លួន ជា ប្រជាពលរដ្ឋ, ជា អំពើ ស្របច្បាប់ ឥត អាច ផ្តន្ទាទោសបាន, ជា ទឹកចិត្ត ប្រកប ដោយ មនសិការ ជាតិ ដែលជា សម្ពាត ទៅលើ អ្នកដឹកនាំ ដើម្បី ប្រយោជន៏ជា តិ។ សេចក្តីក្លាហាននេះ ជា សេចក្តីក្លាហាន សាមញ្ញបំផុត ព្រោះ ឥតចាំបាច់ ប្រើ កម្លាំងបាយ នាំអាចឲមាន គ្រោះថ្នាក់ ដល់ រូបកាយ, គ្រាន់តែមាន ការសំរេចចិត្ត មិន ចូលរួម ការបោះ ឆ្នោត ណា ដែល គ្មានសេរី និង យុត្តិធម៌ តែប៉ុណោះ។ សេចក្តី ក្លាហាននេះ,ខ្មែរម្នាក់ៗ អាចធ្វើបាន ងាយស្រួល ព្រោះ បុគ្គល ម្នាក់ៗ ជា ម្ចាស់ខ្លួនឯងផង, ជា នីតិជន ដែល ជា ម្ចាស់ អំណាចរដ្ឋផង, យើងគ្រាន់តែ សួរថា, តើ ខ្មែរយើង អាចមាន សេចក្តីក្លាហាន នេះដែរ ឬទេ ? បើប្រសិនជា អាចមាន, សេច ក្តីក្លាហាននេះ គឺ ជា ការសង្គ្រោះជាតិ នោះឯងហើយ។ តែ បើ ខ្មែរយើង នាំគ្នា យក ការបោះឆ្នោត ជា ចម្លើយនឹង មហាទុក្ខ របស់ ប្រជាពលរដ្ឋ, ការនេះ ជា សិទ្ធិ របស់ បុគ្គលម្នាក់ៗ ដែល ឥតអាច នរណា ឃាត់ឃាំង បាននោះឡើយ ព្រោះ បុគ្គលម្នាក់ៗ ជា អ្នកទទួលខុសត្រូវផ្ទាល់ លើ អំពើ ដែល ខ្លួនបានធ្វើ។ ក្នុង សេចក្តីក្លាហាននេះ,យើង លើក គណបក្សប្រឆាំង មកពិនិ ត្យមើល ទង្វើ ទាំងឡាយ ដែល គេ កំពុងធ្វើ, គេ នាំគ្នា ធ្វើការ រួបរួម ផ្លែកមួយ គឺ,បំបែក កម្លាំង ពី២ ទៅ៣, និយាយ កុហក ជាអលជ្ជី (គ្មានខ្មាស) ចំពោះ រាស្ត្រ ថា, បើ គ្មាន ការកែទម្រង់

# សង្គ្រាម និង សន្តិភាព

គណកម្មាធិការ ត្រួតពិនិត្យ ការបោះឆ្នោត, បើ គ្មាន វត្តមាន លោក សម រង្ស៊ី នៅស្រុកខ្មែរ ក្នុងពេល ធ្វើយុទ្ធការបោះឆ្នោត ,គេ នឹងនាំគ្នា ធ្វើពហិការ, តែ គេ ដឹងរួច ទៅហើយថា រដ្ឋសភាជាតិ, គេបោះឆ្នោត រក្សាទុក គណកម្មការ ត្រួតពិនិត្យ ការបោះឆ្នោត ឲនៅ ដដែល, ហើយ គណកម្មការនេះ សម្រេចចិត្តលុប ឈ្មោះ លោក សម រង្ស៊ី ពី បញ្ជីបោះឆ្នោត ទៅទៀត, ការនេះ បែជា គេ ធ្វើមិនដឹង, បំភ្លេច សេចក្តី ថ្លែងការណ៍ របស់ខ្លួន, នាំគ្នា ធ្វើយុទ្ធការ បោះឆ្នោត ទុក បណ្តារាស្ត្រ ជាជន ល្ងង់ល្ងើ អាច និយាយ កុហក បានងាយស្រួល, ទង្វើនេះ ជា ការមើលងាយ ចំពោះ ប្រជារាស្ត្រ ខ្លួនឯង។ តែ យើង មិនសូវមាន ការងឿង ឆ្ងល់អ្វី នោះឡើយ ព្រោះថា នៅ ស្រុកខ្មែរយើង សព្វថ្ងៃនេះ, ការភូតកុហក វាក្លាយ ជា វប្បធម៌ជាតិ ទៅហើយ។ ដូច្នេះ ប្រវ័ញ្ចន៏ (អំពើបញ្ឆោត) រក ប្រយោជន៏ សំរាប់ខ្លួន គឺ ចុះនៅក្នុង វប្បធម៌ ភូតកុហក នោះឯង។ សំដី វាលនេះ (និយាយ ឲតែរួចពីមាត់), វា នាំឲ បណ្តារាស្ត្រ បាត់ជំនឿ លើ ការសន្យា ដ៏ទៃទៀត,ដូចយ៉ាង :

ឧបត្ថម អនុស្សចាស់ ពី អាយុ ៦៥ឆ្នាំ (៤ ម៉ឺនរៀល ក្នុង ១ខែ), ប្រាក់ខែ ទាបបំផុត របស់ កម្មករ, កម្មការិនី (៦០ ម៉ឺនរៀល ក្នុង ១ខែ), អ្នករាជការ (១ លានរៀល ក្នុង ១ខែ), ព្យាបាលជម្ងឺ បណ្តារាស្ត្រ ក្រីក្រ ដោយ ឥតយកប្រាក់, បំបាត់ អំពើពុករលួយ, ពង្រឹង វិស័យ អប់រំ និង បង្កើត ការងារ ឲយុវជន។ កម្មវិធីនេះ

## សង្គ្រាម និង សន្តិភាព

គឺ ពិត ជា រុច្ចនៈ (សេចក្ដីគាប់ចិត្ត) របស់ ប្រជាពលរដ្ឋ, តែ វា ខ្វះ ហេតុ ដែលនាំ ឲជឿ (Crédibilité) ព្រោះថា អ្នកសន្យា គ្មាន បាន បង្ហាញ លក្ខណសម្បត្តិ សម្ភារ (ផ្សំ )អ្វីមួយ ឲ បណ្ដារាស្ត្រ ជឿ ខ្លួន ថា អាច មាន ជ័យជំនិះ ក្នុង ការបោះឆ្នោត មួយ ដែល គ្មានសេរី និង យុត្តិធម៌ ដែល ជា ការប្រកួតមួយ មាន អ្នកឈ្នះ រួចស្រេចទៅហើយ គឺ គណបក្ស កាន់អំណាច, ក្នុងការមើល ឃើញនេះឯងហើយ, ដែលនាំឱ្យ យើង យល់ថា ការសន្យានេះ ជា ពាក្យ បំភន្ត័,ហើយ ការចូលរួម បោះឆ្នោត ក្នុងលក្ខណ: បែប នេះ គឺ ជា ការផ្សងព្រេង ឬជា ការភ្នាល់ ក្នុងល្បែង ស៊ីសងមួយ តែប៉ុណ្ណោះ។ ការនេះហើយ ដែលធ្វើឲយើង មាន ការព្រួយបារម្ភ ណ៏ អំពី អនាគតជាតិខ្មែរ! តើ ពេលណាទៅ ខ្មែរយើង នឹងបាន ឮ សម្មាវាចា (parole droite) ពីសំណាក់ អ្នកដឹកនាំ គ្រប់ និន្នាការ នយោបាយ។ មកដល់សព្វថ្ងៃនេះ, ន័យ នយោបាយ សំរាប់រាស្ត្រ គឺ នៅតែមាន សេចក្ដីថា ‹‹នយោបាយ គឺ នយោបោក›› នោះ ឯង។ យើងឃើញហើយថា,នៅស្រុកខ្មែរ,មាន សង្គ្រាមក្ដី ឬមាន សន្តិភាពក្ដី, ក៏រាស្ត្រខ្មែរ នៅតែស្លាប់, មួយស្លាប់នឹង អាវុធ យោធា មួយស្លាប់នឹង អាវុធនយោបាយ, បើ រំគាយ (ឲទូលាយ) ការសង្កេត, ហាក់បីដូចជា ខ្មែរយើង នាំគ្នា ហុច អាវុធ ឲគេ សម្លាប់ ខ្លួនឯង តែម្ដង ព្រោះ ខ្មែរយើង នាំគ្នា រស់ ក្នុង វប្បធម៌បរាជ័យ ជា ប្រជារាស្ត្រ ស្គាល់តែ អាយាចនៈ (ការអង្វរ) សូម រស់ តែមួយគែ, គ្មានអនាគត, ពឹង តែអ្នកកាន់អំណាច, ទោះបី

# សង្គ្រាម និង សន្តិភាព

ដឹងថា អ្នកកាន់អំណាច នោះ ជា លុម្បកជន (ចោរប្លន់) ក៏នៅតែ ទៅអង្វរ សូម អនុគ្រោះ ពីគេ ឲជួយខ្លួន ទាំងអស់សង្ឃឹម។ នេះហើយ ជាអកុសលខ្មែរ! តែ ចម្លែកដែរ, នៅ ប្រទេសយៀកណាម,គេ មាន សង្គ្រាម ស៊ីវីល ផង, សង្គ្រាម រំដោះជាតិផង, សង្គ្រាម នយោបាយផង, តែ សង្គ្រាមទាំងនោះ, បែរជា កត្តា សំរាប់ ការរីកទឹកដីគេទៅវិញ, ខុសពីស្រុកខ្មែរ, ទោះបី មាន សង្គ្រាម ឬ ឥតសង្គ្រាម,ទឹកដីខ្មែរ ចេះតែរួញ ជានិច្ច, ដូចសព្វថ្ងៃនេះ, ឥតមាន សង្គ្រាមសោះ, បែរជា ស្រុកខ្មែរ បាត់បង់ កោះផង, រួញ ទឹកដីផង, ហើយថែម ទាំងមាន ជនជាតិយួន រាប់លាន នាក់ មករស់នៅ ក្នុងទឹកដីខ្មែរផង។ ការនេះ រឹតតែ បញ្ជាក់ ថែមទៀតថា, សង្គ្រាម និង សន្តិភាព នៅស្រុកខ្មែរ គឺ ដូចជា ‹‹បួន និង មួយដំប›› នោះឯង, នៅពេលណា ខ្មែរយើង នៅតែរស់ក្នុង អកម្មភាព ទាំងស្រុង ក្នុង សកម្មភាព នយោបាយជាតិ។ យើង ត្រូវដឹកថា, ប្រជាពលរដ្ឋ មិនមែន ជា អចលវត្ថុ នោះទេ, ដែល អ្នកដឹកនាំ អាច លើកដាក់បាន តាមចំណង់ចិត្តគេ, ប្រជាពលរដ្ឋ ជា កម្លាំង វិរិយោជាតិ, មាន ព្រលឹង ដែល ជាប្រភព នៃ គំនិតវិជ្ជាមាន សំរាប់ រក ប្រយោជន៍ ឲប្រជាជាតិ,ទោះបី ប្រជាជាតិ ធ្លាក់ ក្នុង កលិយុគ សម្លាប់ ព្រលឹងជាតិ, តែ កម្លាំង វិរិយោ ប្រជាពលរដ្ឋ អាចមាន លទ្ធភាព ធ្វើបដិសន្ធិ ឲ ប្រលឹងជាតិ នោះ រស់បានវិញ, នៅពេលណា ដែលខ្មែរម្នាក់ៗ នៅស្គាល់ដឹង ធម៌ក្រិត្យា (គ្រប់ កតប្បកិច្ច) របស់

# សង្គ្រាម និង សន្តិភាព

ប្រជាពលរដ្ឋ ដែល ជា គោល មួយ របស់ប្រជាជាតិ។ យើងគ្មាន គោលបំណងនឹងឲ មេរៀន ដល់ ខ្មែរណា នោះឡើយ ព្រោះ យើង តែង គោរព ជានិច្ច គ្រប់គំនិតណា ដែល យក ប្រយោជន៏ជាតិ ជាបារមិត (vertu suprême), តែ យើង ក៏ពុំអាច នៅស្ងៀម នៅ ចំពោះមុខ គ្រប់គំនិតណា ឬ អំពើណា ជា មោហោគ្តី, ជា ចេតនាគ្តី ដែលនាំ បំផ្លាញ ជាតិខ្មែរ។ យើង គ្មានចង់បាន ប្រយោជន៏ អ្វីសោះនោះឡើយ ក្នុង ការបញ្ចេញទស្សនះយើង នេះ, បំណងតែមួយគត់ ដែល យើងមាន គឺ រស់ ជា សេរីជន, គ្មានម្ចាស់, គ្មានចៅហ្វាយ, ហើយមាន សត្រូវតែមួយគត់ គឺ សត្រូវជាតិខ្មែរ តែប៉ុណ្ណោះ។ ដូច្នេះ ក្នុងឆ្នាំថ្មី ២០១៣ នេះ, យើង ធ្វើចំរើនរពរ (ពរឲមានសុភមង្គល និង មានវិបុលភាព) ដល់ ប្រជាពលរដ្ឋខ្មែរ,ជា ពិសេសដល់ លោក ម៉មសាណង់ដូ សូម ឲលោក ចាកផុតពី អំពើ អយុត្តិធម៌ ដែល លោក កំពុងជួប ប្រទះ,ដែលជា អំពើ និរគុណមួយ ឥតអាច យល់បាន។ សូមឲ ប្រជាជាតិខ្មែរ នឹងមាន សេរីយស នៅចំពោះមុខ សត្រូវជាតិ ទាំងឡាយ៕